# មាតិកា

## I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម

០៣-៧-២០០៩ -ព្រះរាជក្រម នស/រកម/០៧០៩/០១១ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីការជំរុញ និង ការការពារវិនិយោគ ៤៨១៨

### ២-ព្រះរាជក្រឹត្យ

២៦-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៩៦ ស្តីពីការតែងតាំងលោកជំទាវ **ស៊ិន ចរិយាសម្ផស្ស** ជាទីប្រឹក្សាក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៤៨៣៩

២៦-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៦៩៨ ស្តីពីការតែងតាំងឯកឧត្តមចំនួន ០២ រូប ជាប្រធាន និង អនុប្រធាន នៃអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល មានឋានៈស្មើ អគ្គនាយក ៤៨៤០

២៦-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៧០១ ស្តីពីការតែងតាំងឯកឧត្តម **ចាន យ៉ុខ ដូ** ជាជំនួយការឯកឧត្តម **លី ធុជ** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានគណៈកម្មាធិការជាតិអេស្កាប់ មានឋានៈស្មើ អគ្គនាយក ជំនួសឯកឧត្តម **ចៅ ឡាយ** ដែលត្រូវបានទទួលភារកិច្ចថ្មី ៤៨៤១

២៦-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៧០២ ស្តីពីការតែងតាំងឯកឧត្តម **អ៊ុត ផាន់** ជាទីប្រឹក្សាអមក្រសួងអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៤៨៤២

២៦-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៧០៣ ស្តីពីការតែងតាំងឯកឧត្តម **ស៊ុត ឌីណា** ជាអនុរដ្ឋលេខាធិការ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ៤៨៤៣

២៦-៦-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៦០៩/៧០៤ ស្តីពីការតែងតាំងឯកឧត្តម **ស៊ុត ឌីណា** ជាទីប្រឹក្សាផ្ទាល់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៤៨៤៤

## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៧៣ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកអង្គរជ័យនៃខេត្តកំពត ៤៨៤៥

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៧៤ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ក្រុងកំពត នៃខេត្តកំពត ៤៨៤៧

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៧៥ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកឈូក នៃខេត្តកំពត ៤៨៤៩

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៧៦ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកដងទង់ នៃខេត្តកំពត ៤៨៥១

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៧៧ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកកំពង់ត្រាច នៃខេត្តកំពត ៤៨៥៣

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៧៨ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកបន្ទាយមាស នៃខេត្តកំពត ៤៨៥៥

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៧៩ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកជុំគិរី នៃខេត្តកំពត ៤៨៥៧

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៨០ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកទឹកឈូ នៃខេត្តកំពត ៤៨៥៩

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៨១ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ក្រុងស្ទឹងត្រែង នៃខេត្តស្ទឹងត្រែង ៤៨៦១

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៨២ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកថាឡាបរិវ៉ាត់ នៃខេត្តស្ទឹងត្រែង ៤៨៦៣

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៨៣ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកសៀមប៉ាង នៃខេត្តស្ទឹងត្រែង ៤៨៦៥

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៨៤ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកសៀមបូក នៃខេត្តស្ទឹងត្រែង ៤៨៦៧

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៨៥ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកសេសាន នៃខេត្តស្ទឹងត្រែង ៤៨៦៩

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៨៦ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុករុក្ខគិរី នៃខេត្តបាត់ដំបង ៤៨៧១

# គ

២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៨៧ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ក្រុងបាត់ដំបង នៃខេត្តបាត់ដំបង ៤៨៧៣
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៨៨ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកមោងឫស្សី នៃខេត្តបាត់ដំបង ៤៨៧៥
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៨៩ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកបាណន់ នៃខេត្តបាត់ដំបង ៤៨៧៧
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៩០ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកបវេល នៃខេត្តបាត់ដំបង ៤៨៧៩
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៩១ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកថ្មគោល នៃខេត្តបាត់ដំបង ៤៨៨១
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៩២ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកឯកភ្នំ នៃខេត្តបាត់ដំបង ៤៨៨៣
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៩៣ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកសង្កែ នៃខេត្តបាត់ដំបង ៤៨៨៥
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៩៤ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុករតនមណ្ឌល នៃខេត្តបាត់ដំបង ៤៨៨៧
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៩៥ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកគាស់ក្រឡ នៃខេត្តបាត់ដំបង ៤៨៨៩
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៩៦ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកកំរៀង នៃខេត្តបាត់ដំបង ៤៨៩១
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៩៦ អនក្រ.តត (ស្ទួន) ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ៤៨៩៣
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៩៧ អនក្រ.តត ស្តីពីការជូនមេដាយមាសការងារ ៤៨៩៥
២៨-៥-២០០៩ -អនុក្រឹត្យលេខ ៩៩៨ អនក្រ.តត ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សា ស្រុកសំឡូត នៃខេត្តបាត់ដំបង ៤៨៩៧

## III. ការងារបណ្ដាក្រសួង

### ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២១-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៦៣២ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **នៃគវ៉េល ផាត ខូ អិលធីឌី** ៤៨៩៩

២១-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៦៣៣ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់សាខាក្រុមហ៊ុន **ដើរ អេន ម៉ាស៊ីន អ៊ីនជីនារីង លីមីធីត ផាតនើស៊ីប** ៤៩០១

២១-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៦៤៧ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **គ្លូប៊ល ម៉នីង ស៊ីធី** ៤៩០៣

២១-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៦៤៨ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ញូ ខិតឌី ខមភេនី** ៤៩០៥

២១-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៦៤៩ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **យូនៀន បូវ៉ូ អហ្វ សីបតឹង** ៤៩០៧

២១-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៦៥០ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហ្វ្រីន ហ្វស** ៤៩០៩

២១-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៦៥១ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ខេមបូឌាន ឆាយណា អ៊ិនធើណេសិនណល ម៉ាញូ រីសសស៍ ឌីវេឡុបមេន គ្រុប** ៤៩១១

២១-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៦៥៣ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ឌី អ ស្កាយ ហាយ** ៤៩១៣

២១-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៦៥៤ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហេដុង (ខេមបូឌា) អេនជីនារីង & ខន ស្ត្រាក់សិន** ៤៩១៥

២១-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៦៦២ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អាន ត្រេឌីង គ្រុប** ៤៩១៧

២២-១០-២០០៨ -លិខិតបញ្ជាក់លេខ ៥៦៦៨ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **រ៉ូយ៉ាល់ ចេនឡា អ៊ិនធើណេសិនណល គ្រុប** ៤៩១៩

# ព្រះរាជក្រម

នស/រកម/០៧០៩/០១១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីការជំរុញ និងការការពារវិនិយោគ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៩ នាសម័យប្រជុំវិសាមញ្ញ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋ ប្រជាធិបតេយ្យប្រជាមានិតឡាវស្តីពីការជំរុញ និងការការពារវិនិយោគ

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីពីការជំរុញ និងការការពារវិនិយោគ ដែលធ្វើនៅក្រុងវៀងច័ន្ទ នាថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០៩

នស/រកម.០៧០៩.៣៩១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**ហត្ថលេខា**

**គាត ឈន់**

លេខ: [illegible] ច.ល
[illegible] ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ២០០៩
[illegible] រាជរដ្ឋាភិបាល
[illegible] កេន

# កិច្ចព្រមព្រៀង
# រវាង
# រាជរដ្ឋាភិបាលកម្ពុជា
# និង
# រដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
# ស្តីពី
# ការជំរុញ និង ការការពារវិនិយោគ

*******

**រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ** (ចាប់ពីពេលនេះតទៅ ហៅថា "**ភាគីជាប់កិច្ចសន្យា**")

ក្នុងស្មារតីលើកកំពស់ចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេស និងប្រជាជន នៃប្រទេសទាំងពីរ

ដោយមានបំណងបង្កើតនូវលក្ខខ័ណ្ឌអនុគ្រោះសំរាប់កិច្ចដំណើរការវិនិយោគ ដែលធ្វើឡើងដោយជនជាតិរបស់ភាគីជាប់កិច្ចសន្យាមួយ ឈរលើមូលដ្ឋានអធិបតេយ្យភាព ស្មើភាព និងមានផលប្រយោជន៍ទៅវិញទៅមក និង

ដោយទទួលស្គាល់ថា កិច្ចព្រមព្រៀងស្តីពីការជំរុញ និងការការពារវិនិយោគនេះ នឹងជំរុញឱ្យមានការកើនឡើងនូវសកម្មភាពផ្នែកវិនិយោគនៅក្នុងប្រទេសទាំងពីរ ។

**បានព្រមព្រៀងគ្នា ដូចតទៅ :**

មាត្រា ១

## និយមន័យ

## គោលបំណងនៃកិច្ចព្រមព្រៀង

១- ពាក្យ "**វិនិយោគ**" សំដៅដល់ ទ្រព្យសម្បត្តិ ដែលបានវិនិយោគដោយជនជាតិនៃភាគីជាប់កិច្ចសន្យាមួយ នៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត និងបានការអនុញ្ញាតដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិ នានារបស់ភាគីជាប់កិច្ចសន្យា ដែលក្នុងនោះរួមមាន ទ្រព្យសម្បត្តិដូចខាងក្រោម តែមិនក៏រឹតទាំងស្រុងត្រឹមទ្រព្យសម្បត្តិទាំងនោះឡើយ :

ក- ចលនទ្រព្យ និងអចលនទ្រព្យព្រមទាំងសិទ្ធិកាន់កាប់ដទៃទៀត ដូចជា ការបញ្ចាំ បុព្វសិទ្ធិ និងការធានា ព្រមទាំងសិទ្ធិដទៃទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល

ខ- សិទ្ធិជាភាគហ៊ុន ប័ណ្ណធានា ឬផលប្រយោជន៍ផ្សេងទៀត នៅក្នុងក្រុមហ៊ុននៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត

គ- សិទ្ធិលើភាគហ៊ុន ប័ណ្ណធានា ឬប្រតិបត្តិការណាមួយ ដែលមានតំលៃហិរញ្ញវត្ថុ

ឃ- កម្មសិទ្ធិបញ្ញា ក្បួនខ្នាតបច្ចេកវិទ្យា កិត្តិនាមជំនួញ និង ចំណេះដឹងផ្សេងៗ

ង- សម្បទានធុរៈកិច្ចមានតំលៃសេដ្ឋកិច្ចដែលទទួលស្គាល់ដោយច្បាប់ ឬតាមកិច្ចសន្យាទាក់ទិននឹងការវិនិយោគ ដោយរួមទាំងសម្បទានសំរាប់ការស្រាវជ្រាវ ឬការធ្វើអាជីវកម្មធនធានធម្មជាតិ ។

ការប្តូរទ្រង់ទ្រាយនៃទ្រព្យសម្បត្តិដែលបានវិនិយោគ មិនត្រូវមានឥទ្ធិពលទៅលើចរិតនៃការវិនិយោគ ដែលបានផ្តល់ជូនឡើយ ក្នុងពេលដែលការប្តូរទ្រង់ទ្រាយនោះត្រូវបានឯកភាព និងទទួលស្គាល់ក្រោមមាត្រា ២ នៃកិច្ចព្រមព្រៀងនេះ ។

២- ពាក្យ "**ជនជាតិ**" សំដៅដល់

(១) រូបវន្តបុគ្គលដែលមានសញ្ជាតិរបស់ភាគីជាប់កិច្ចសន្យា

(២) នីតិបុគ្គលដែលបង្កើតឡើងក្រោមច្បាប់នៃភាគីជាប់កិច្ចសន្យា ។

៣- ពាក្យ "**គ្មានការពន្យារពេល**" សំដៅដល់ រយៈពេលដែលជាធម្មតាតម្រូវឱ្យមាន សំរាប់បំពេញទំរង់បែបបទចាំបាច់ដើម្បីផ្ទេរប្រាក់ ។

៤- ពាក្យ "**ទឹកដី**" សំដៅដល់

ក- ចំពោះព្រះរាជាណាចក្រកម្ពុជា : ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលរាប់បញ្ចូលទាំងតំបន់សមុទ្រ រួមមាន ខ្ពង់រាបបាតសមុទ្រ និងស្រទាប់ដីក្រោមបាតសមុទ្រ ដែលជាប់នឹងដែនសមុទ្រខាងក្រៅ ហើយដែលព្រះរាជាណាចក្រកម្ពុជាមានអធិបតេយ្យភាព និងកាតព្វកិច្ចគ្រប់គ្រងតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

ខ- ចំពោះសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ : ទឹកដីទាំងអស់ ដែលសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ មានអធិបតេយ្យលើ ឬគ្រប់គ្រងតាមផ្លូវច្បាប់ អនុលោមតាមច្បាប់អន្តរជាតិ។

៥- ពាក្យ "**ផលពីការធ្វើវិនិយោគ**" សំដៅដល់ ចំណូលដែលបានមកពីការវិនិយោគ ក្នុងរយៈពេលកំណត់មួយ ដូចជា ប្រាក់ចំណេញ ការប្រាក់ ផលកំរៃនៃទុន ប្រាក់ចំណេញនៃភាគហ៊ុន កំរៃឈ្នួល និងកំរៃផ្សេងទៀត ដែលទទួលបានដោយស្របច្បាប់។

៦- ពាក្យ "**រូបិយប័ណ្ណប្រើប្រាស់ដោយសេរី**" សំដៅដល់ រូបិយប័ណ្ណ ដុល្លារអាមេរិក, ផោនស្ទែកលីងអង់គ្លេស, ម៉ាកអាល្លឺម៉ង់, ហ្វ្រង់បារាំង, យ៉េនជប៉ុន ឬ រូបិយប័ណ្ណផ្សេងទៀត ដែលប្រើប្រាស់ទូលាយក្នុងការទូទាត់ជាអន្តរជាតិ និងដែលធ្វើអាជីវកម្មជាទូទៅនៅលើទីផ្សារប្តូរប្រាក់អន្តរជាតិសំខាន់ៗ។

## មាត្រា ២

## ការជំរុញ និង ការការពារវិនិយោគ

១- ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវលើកទឹកចិត្ត និងបង្កើតលក្ខខណ្ឌអនុគ្រោះដល់ជនជាតិនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ក្នុងការធ្វើវិនិយោគលើទឹកដីរបស់ខ្លួន ហើយត្រូវផ្តល់ការអនុញ្ញាតដល់ការវិនិយោគនោះ ដោយអនុលោមតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន។

២- រាល់ការវិនិយោគ ដែលធ្វើឡើងដោយជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយត្រូវទទួលបាននូវប្រព្រឹត្តិកម្មដោយយុត្តិធម៌ និងសមភាពគ្រប់ពេលវេលា ហើយត្រូវទទួលបាននូវការការពារ និងសន្តិសុខពេញលេញនៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត។

## មាត្រា ៣
## បញ្ញត្តិទាក់ទងនឹងប្រជាជាតិទទួលការអនុគ្រោះបំផុត

១- ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវធានាផ្តល់នូវប្រព្រឹត្តកម្មដោយយុត្តិធម៌ និងសមភាព លើការធ្វើវិនិយោគរបស់ជនជាតិនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត និងមិនធ្វើឱ្យខូចប្រយោជន៍ដោយវិធានការមិនសមហេតុផល ឬរើសអើងចំពោះប្រតិបត្តិការ ការគ្រប់គ្រង ការថែរក្សា ការប្រើប្រាស់ ការទទួលផល ឬ ការចាត់ចែងវិនិយោគរបស់ជនជាតិទាំងនោះទេ។ ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវយល់ព្រមផ្តល់នូវការការពារសន្តិសុខគ្រប់គ្រាន់ដល់ការវិនិយោគនោះ។

២- សំខាន់ជាងនេះ ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវផ្តល់ប្រព្រឹត្តិកម្មលើវិនិយោគនៅគ្រប់ករណី ដែលភាពអនុគ្រោះនោះ មិនតិចជាងអ្វីដែលខ្លួនបានផ្តល់ឱ្យចំពោះការវិនិយោគ ដែលធ្វើឡើងដោយជនជាតិ នៃរដ្ឋទីបីឡើយ។

៣- ប្រសិនបើភាគីជាប់កិច្ចសន្យាមួយ បានផ្តល់នូវអត្ថប្រយោជន៍ពិសេសដល់ជនជាតិនៃរដ្ឋទីបីណាមួយ តាមរយៈកិច្ចព្រមព្រៀងដែលមានស្រាប់ ឬកិច្ចព្រមព្រៀងនាពេលអនាគតក្នុងការបង្កើតនូវ សហព័ន្ធគយ សហព័ន្ធសេដ្ឋកិច្ច សហព័ន្ធរូបិយវត្ថុ ឬស្ថាប័នស្រដៀងៗគ្នានោះ ភាគីជាប់កិច្ចសន្យានោះនឹងពុំត្រូវបង្ខំឱ្យទទួលកាតព្វកិច្ចក្នុងការផ្តល់អត្ថប្រយោជន៍ដូចគ្នាខាងលើនេះ ដល់ជនជាតិនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតឡើយ។

៤- ខ្លឹមសារទាំងឡាយនៃមាត្រានេះ នឹងមិនអនុវត្តចំពោះករណីពន្ធដារ នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យានីមួយៗទេ។ ករណីខាងលើនេះ នឹងត្រូវគ្រប់គ្រងតាមរយៈសន្ធិសញ្ញាស្តីពីការបញ្ចៀសការបង់ពន្ធត្រួតគ្នារវាងភាគីជាប់កិច្ចសន្យាទាំងពីរ និងច្បាប់ក្នុងស្រុករបស់ភាគីជាប់កិច្ចសន្យានីមួយៗ។

## មាត្រា ៤
## ការដកហូត

ភាគីជាប់កិច្ចសន្យានីមួយៗ មិនអាចចាត់វិធានការណាមួយ ដើម្បីធ្វើការដកហូតទ្រព្យសម្បត្តិ តាមវិធីជាតូបនីយកម្ម ឬស្ថិតក្រោមវិធានការដកហូតសិទ្ធិណាមួយផ្សេងទៀត ដែលមានឥទ្ធិពលដូចគ្នាទៅនឹងជាតូបនីយកម្ម ឬការរឹបអូស ចំពោះការវិនិយោគរបស់ជនជាតិ នៃភាគីជាប់កិច្ចសន្យាម្ខាងទៀតបានឡើយ លើកលែងតែក្នុងលក្ខខណ្ឌ ដូចខាងក្រោមនេះ :

ក- រាល់វិធានការដែលអនុវត្តសំដៅឱ្យមានការគោរពច្បាប់ ដើម្បីជាផលប្រយោជន៍សាធារណៈ ដោយស្រប ទៅតាមនីតិវិធីនៃច្បាប់

ខ- រាល់វិធានការដែលគ្មានការរើសអើង

គ- រាល់វិធានការដែលភ្ជាប់ដោយបញ្ញត្តិនានា

សំរាប់ការទូទាត់លើការខូចខាតប្រកបដោយប្រសិទ្ធិភាពគ្រប់គ្រាន់ និងឆាប់រហ័ស។ សំណងនេះ ត្រូវធ្វើឡើងដោយផ្អែកលើតំលៃទីផ្សារត្រឹមត្រូវនៃការធ្វើវិនិយោគ នៅមុនពេលដែលវិធានការ ដកហូតនេះត្រូវបានដឹងជាសាធារណៈ។ តំលៃទីផ្សារនោះ ត្រូវបានកំណត់ឱ្យសមស្របទៅតាម វិធីសាស្រ្ត ដែលទទួលស្គាល់ជាអន្តរជាតិ ឬប្រសិនបើតំលៃទីផ្សារមិនអាចកំណត់បានទេនោះ ការ ប៉ះប៉ូវនឹងត្រូវកំណត់តាមទឹកប្រាក់សមស្រប ដែលភាគីទាំងពីរបានព្រមព្រៀងគ្នាទៅវិញទៅមក ហើយទឹកប្រាក់នោះអាចផ្ទេរបានដោយសេរី និងគិតជារូបិយវត្ថុដែលអាចប្រើប្រាស់បានដោយសេរី ពីភាគីជាប់កិច្ចសន្យា។

## មាត្រា ៥
## ការទូទាត់សងចំពោះការខាតបង់

១- ជនជាតិទាំងអស់នៃភាគីជាប់កិច្ចសន្យាណាមួយ ដែលធ្វើវិនិយោគលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាង ទៀត ដែលទទួលរងនូវការខាតបង់ដោយសារសង្គ្រាម ឬជំលោះប្រដាប់អាវុធ បដិវត្តន៍ ឬការប្រកាស ដាក់ប្រទេសជាតិក្នុងភាពអាសន្ន ការបះបោរ កុប្បកម្ម ឬភាពចលាចល នៅក្នុងទឹកដីនៃភាគីម្ខាងទៀត ដែលខ្លួនធ្វើវិនិយោគ នឹងត្រូវបានទទួលពីភាគីជាប់កិច្ចសន្យានោះនូវប្រព្រឹត្តិកម្ម ដូចជា ការសងវិញនូវ សំណង ការទូទាត់សង ឬ ដំណោះស្រាយផ្សេងៗទៀត។

២- ប្រព្រឹត្តិកម្មនេះ មិនត្រូវតិចជាងអ្វីដែលភាគីជាប់កិច្ចសន្យានោះ បានផ្តល់ឱ្យជនជាតិរបស់ខ្លួន ឬជនជាតិ នៃរដ្ឋទីបី ពោលគឺផ្តល់នូវភាពអនុគ្រោះណាមួយ ដែលមានលក្ខណៈប្រសើរជាង។

## មាត្រា ៦
## ការផ្ទេរ

១- ភាគីជាប់កិច្ចសន្យានីមួយៗ ដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន ត្រូវអនុញ្ញាតឱ្យមាន ការផ្ទេរដោយសេរី ដោយគ្មានការពន្យាពេលពុំសមហេតុផលនូវអ្វីដែលបានមកពីការវិនិយោគ ដែលធ្វើ

ឡើងដោយ ជនជាតិនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត។ ការផ្ទេរនោះត្រូវរាប់បញ្ចូលនូវចំណុចដូចខាងក្រោម តែមិនកំណត់ត្រឹមនេះទេ :

ក- ប្រាក់ចំណេញ ការប្រាក់ ប្រាក់ចំណេញនៃភាគហ៊ុន និងប្រាក់ចំណូលផ្សេងទៀត ដែលបានមកពីវិនិយោគ

ខ- មូលនិធិចាំបាច់

(១) សំរាប់ទិញវត្ថុធាតុដើម ឬសំភារៈបន្ទាប់បន្សំ ផលិតផលពាក់កណ្តាលសំរេច ឬ ផលិតផលសំរេច ឬ

(២) ជំនួសទុនវិនិយោគ សំដៅធានានិរន្តភាពនៃដំណើរការវិនិយោគ

គ- មូលនិធិបន្ថែមចាំបាច់សំរាប់អភិវឌ្ឍន៍ ដំណើរការវិនិយោគ

ឃ- មូលនិធិក្នុងការទូទាត់សង ប្រាក់កម្ចី ចំពោះការវិនិយោគ ដែលទទួលបានការអនុញ្ញាត

ង- កំរៃសួយសារ ឬកំរៃផ្សេងៗ

ច- ចំណូលរបស់រូបវន្តបុគ្គល

ឆ- ចំណូលដែលបានមកពីការលក់ ឬ ការរំលាយក្រុមហ៊ុនវិនិយោគ

ជ- ការទូទាត់សងចំពោះការខាតបង់ ដោយអនុលោមតាមមាត្រា ៥

ឈ- ការទូទាត់សងចំពោះការដកហូត ដោយអនុលោមតាមមាត្រា ៤

២- រាល់ការផ្ទេរណាមួយដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះ នឹងត្រូវអនុវត្តតាមរយៈរូបិយប័ណ្ណដែលងាយប្តូរបានដោយសេរី។ អត្រាប្តូរប្រាក់ចំពោះការផ្ទេរនោះនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ នឹងត្រូវធ្វើតាមអត្រាប្តូរប្រាក់ ដែលមានជាធរមាននៅពេលផ្ទេរ។

## មាត្រា ៧

## ឧបាទេសកម្ម

ក្នុងករណីដែលភាគីជាប់កិច្ចសន្យាមួយ បានផ្តល់នូវការធានារ៉ាប់រង ឬកិច្ចព្រមព្រៀងធានាណាមួយការពារ ដល់ហានិភ័យមិនមែនពាណិជ្ជកម្មទាក់ទងនឹងការវិនិយោគ ដែលបានធ្វើដោយវិនិយោគិនរបស់ខ្លួននៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ហើយការផ្តល់នូវការទូទាត់ជូនវិនិយោគិនក្រោមកិច្ចព្រមព្រៀង

ធានានោះ ភាគីម្ខាងទៀតត្រូវទទួលស្គាល់ការផ្ទេរសិទ្ធិ ដែលមានតំលៃសេដ្ឋកិច្ចរបស់វិនិយោគិននៃភាគីជាប់កិច្ចសន្យានោះ។ ឧបាទេសកម្មនឹងអាចធ្វើបានសំរាប់ភាគីជាប់កិច្ចសន្យាមួយ ដើម្បីទទួលយកសំណងនៃការទូទាត់សងដែលវិនិយោគិនមានសិទ្ធិទទួល ។ ប៉ុន្តែឧបាទេសកម្មនេះ មិនចាំបាច់តំរូវឱ្យមានការទទួលស្គាល់ពីភាគីជាប់កិច្ចសន្យាម្ខាងទៀត អំពីគុណសម្បត្តិ ឬបរិមាណទឹកប្រាក់ដែលកើតចេញពីការទាមទារណាមួយឡើយ ។

ដោយគោរពដល់កម្មសិទ្ធិបញ្ញា ឬសិទ្ធិផ្សេងទៀតដែលបានមកពីភាពជាម្ចាស់នៃការវិនិយោគ ឧបាទេសកម្ម នឹងអាចអនុវត្តបានក្រោយពេលដែលតំរូវការផ្នែកច្បាប់សំរាប់ការវិនិយោគរបស់ប្រទេសម្ចាស់ផ្ទះ ត្រូវបានបំពេញ ។

## មាត្រា ៨

## ដំណោះស្រាយវិវាទរវាងភាគីជាប់កិច្ចសន្យា និងជនជាតិ

១- វិវាទណាមួយដែលកើតឡើងរវាងភាគីជាប់កិច្ចសន្យាណាមួយ ជាមួយជនជាតិនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដែលទាក់ទងដល់កិច្ចការវិនិយោគរបស់ខ្លួន នៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនោះ នឹងត្រូវដោះស្រាយដោយមិត្តភាព តាមរយៈការពិគ្រោះយោបល់ និងការចរចា ។

២- ប្រសិនបើវិវាទនោះមិនអាចដោះស្រាយបាន ក្នុងរយៈពេល ៦ ខែ ចាប់ពីពេលជូនដំណឹងជាលាយលក្ខណ៍អក្សរពីសំណាក់ភាគីណាមួយ ដែលស្នើសុំឱ្យមានដំណោះស្រាយជាមិត្តភាពទេនោះ វិវាទនោះនឹងត្រូវបញ្ជូនតាមនីតិវិធីច្បាប់នៃភាគីជាប់កិច្ចសន្យាពាក់ព័ន្ធ ឬបញ្ជូនទៅមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាលអន្តរជាតិ ឬទៅរកការសម្រុះសម្រួលអន្តរជាតិ ទៅតាមសំណើររបស់ជនជាតិពាក់ព័ន្ធ។

៣- ក្នុងករណីវិវាទត្រូវបានបញ្ជូនទៅមជ្ឈត្តវិនិច្ឆ័យ ឬទៅរកការផ្សះផ្សារណាមួយ ជនជាតិពាក់ព័ន្ធមានសិទ្ធិដាក់ពាក្យបណ្តឹងនោះទៅ :

ក- មជ្ឈមណ្ឌលអន្តរជាតិទទួលបន្ទុកដោះស្រាយវិវាទវិនិយោគ ក្រោមអនុសញ្ញាស្តីពីដំណោះស្រាយវិវាទ វិនិយោគរវាងរដ្ឋ និងជនជាតិនៃរដ្ឋនានា ដែលបានបើកចំហរការចុះកិច្ចសន្យា នៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី កាលពីថ្ងៃទី១៨ ខែមិនា ឆ្នាំ១៩៦៥ សំរាប់ករណីដែលភាគីជាប់កិច្ចសន្យាទាំងពីរបានចូលជាសមាជិកនៃអនុសញ្ញានេះរួចហើយ ឬ

ខ- តុលាការពិសេស ដែលបានបង្កើតឡើងតាមវិធាននៃច្បាប់អាជ្ញាកណ្តាល របស់គណៈកម្មការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ (UNCITRAL)។ ការសំរេចរបស់មជ្ឈត្តករ គឺជាការសំរេចចុងក្រោយ ហើយដែលភាគីវិវាទទាំងពីរត្រូវគោរពតាម ។

៤- គ្មានភាគីជាប់កិច្ចសន្យាណាមួយ អាចស្វែងរកការសម្របសម្រួលតាមរយៈការទូតបានទេ រហូតដល់កិច្ចដំណើរការនៃការកាត់ក្តីត្រូវបានបញ្ចប់ ឬ ភាគីជាប់កិច្ចសន្យាណាមួយ ខកខានក្នុងការគោរព ឬអនុវត្តតាមសេចក្តីសំរេចរបស់តុលាការអាជ្ញាកណ្តាល។

## មាត្រា ៩
## ការដោះស្រាយវិវាទរវាងភាគីជាប់កិច្ចសន្យា

១- វិវាទរវាងភាគីជាប់កិច្ចសន្យា ដែលទាក់ទងដល់ការបកស្រាយ ឬការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ត្រូវដោះស្រាយតាមរយៈការទូត បើសិនធ្វើបាន។

២- ប្រសិនបើវិវាទនោះមិនអាចដោះស្រាយបាន វិវាទនោះត្រូវស្នើឡើងដោយភាគីជាប់កិច្ចសន្យាណាមួយទៅតុលាការអាជ្ញាកណ្តាល។

៣- តុលាការអាជ្ញាកណ្តាល ត្រូវបានបង្កើតឡើងទៅតាមករណីដោយឡែកៗ តាមរបៀបដូចតទៅ : ក្នុងរយៈពេល ២ ខែ ចាប់ពីពេលទទួលពាក្យបណ្តឹង ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវតែងតាំងសមាជិករបស់ខ្លួនម្នាក់ ទៅក្នុងតុលាការអាជ្ញាកណ្តាលនោះ។ បន្ទាប់មកសមាជិកទាំងពីររូប ត្រូវជ្រើសរើសជនជាតិនៃរដ្ឋទីបី ម្នាក់ ដែលមានទំនាក់ទំនងការទូតជាមួយភាគីជាប់កិច្ចសន្យាទាំងពីរ ដោយមានការយល់ព្រមពីភាគីជាប់កិច្ចសន្យា ដើម្បីធ្វើជាប្រធានតុលាការអាជ្ញាកណ្តាល។ ប្រធានតុលាការអាជ្ញាកណ្តាលនេះត្រូវតែងតាំងឱ្យបានរួចរាល់ក្នុងរយៈពេល ២ ខែ គិតពីថ្ងៃដែលសមាជិកតុលាការទាំងពីរ បានតែងតាំងរួចមក។

៤- បើក្នុងរយៈពេលដែលបានកំណត់ក្នុងកថាខ័ណ្ឌ៣ នៃមាត្រានេះ ការតែងតាំងជាចាំបាច់នោះមិនអាចធ្វើបាន ហើយបើគ្មានកិច្ចព្រមព្រៀងដោយឡែកណាទៀតនោះ ភាគីជាប់កិច្ចសន្យានីមួយៗ អាចអញ្ជើញប្រធានតុលាការយុត្តិធម៌អន្តរជាតិឱ្យធ្វើជាប្រធាន។ ប្រសិនបើប្រធានតុលាការនោះជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ ឬមិនអាចបំពេញមុខងារនេះបានដោយប្រការណាមួយនោះ អនុប្រធានតុលាការត្រូវបានអញ្ជើញឱ្យធ្វើជាប្រធាន។ ប្រសិនបើអនុប្រធាននោះ គឺជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ

ឬមិនអាចបំពេញកិច្ចការខាងលើបាន នោះសមាជិករបស់តុលាការយុត្តិធម៌អន្តរជាតិ ដែលមានឋានៈបន្ទាប់តែមិនមែនជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ ត្រូវបានអញ្ជើញឱ្យធ្វើជាប្រធាន។

៥- តុលាការអាជ្ញាកណ្តាលត្រូវកំណត់នីតិវិធីការងារសំរាប់ដំណើរការរបស់ខ្លួន និងត្រូវធ្វើការសំរេចក្តី ដោយការបោះឆ្នោតយកសំឡេងភាគច្រើន។ ការសំរេចក្តីនោះ ត្រូវមានប្រសិទ្ធិភាពអនុវត្តសំរាប់ភាគីជាប់កិច្ចសន្យាទាំងពីរ។

៦- ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវទទួលរ៉ាប់រងនូវសោហ៊ុយចំណាយសំរាប់សមាជិកអាជ្ញាកណ្តាលរបស់ខ្លួន និងសំរាប់អ្នកតំណាងរបស់ខ្លួន ក្នុងដំណើការដំណោះស្រាយវិវាទរបស់អាជ្ញាកណ្តាល។ សោហ៊ុយចំណាយទៅលើប្រធានតុលាការអាជ្ញាកណ្តាល និងចំណាយផ្សេងទៀត គឺជាបន្ទុកដែលភាគីទាំងពីរត្រូវទទួលរ៉ាប់រងស្មើគ្នា។ ប៉ុន្តែ តុលាការអាចធ្វើការសំរេចក្តីឱ្យភាគីជាប់កិច្ចសន្យាណាមួយ ចេញសោហ៊ុយចំណាយច្រើនជាងភាគីម្ខាងទៀត។ ការសំរេចក្តីរបស់តុលាការ គឺជាការសំរេចចុងក្រោយដែលភាគីទាំងពីរត្រូវអនុវត្តតាម។

## មាត្រា ១០

## វិសាលភាព នៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះមានវិសាលភាពចំពោះការវិនិយោគ នៃភាគីជាប់កិច្ចសន្យាណាមួយដែលធ្វើ និងបានទទួលស្គាល់នៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាណាមួយ ដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិដែលទាក់ទងនឹងវិនិយោគបរទេស ឬច្បាប់ដែលបានធ្វើវិសោធនកម្មជំនួសច្បាប់នោះ ប៉ុន្តែមិនអាចអនុវត្តចំពោះរាល់វិវាទ ការតវ៉ា និង វិវាទផ្សេងទៀត ដែលបានកើតឡើងមុនការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះឡើយ។

## មាត្រា ១១

## ការអនុវត្តន៍បញ្ញត្តិផ្សេងទៀត

ប្រសិនបើបញ្ញត្តិនៃច្បាប់របស់ភាគីជាប់កិច្ចសន្យាណាមួយ ឬកាតព្វកិច្ចក្រោមច្បាប់អន្តរជាតិ ដែលមានក្នុងពេលបច្ចុប្បន្ន ឬនឹងត្រូវបានបង្កើតនាពេលអនាគតរវាងភាគីជាប់កិច្ចសន្យាទាំងពីរ ដើម្បីបំពេញបន្ថែមលើកិច្ចព្រមព្រៀងបច្ចុប្បន្ន ហើយបានចែងនូវបទប្បញ្ញត្តិមានលក្ខណៈទូទៅ ឬពិសេសសំរាប់ការងារវិនិយោគរបស់ជនជាតិនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដែលផ្តល់ឱ្យនូវប្រព្រឹត្តកម្មមានអំណោយផលជាងអ្វីដែលបានផ្តល់

ដោយកិច្ចព្រមព្រៀងបច្ចុប្បន្ន បទប្បញ្ញត្តិនោះត្រូវផ្តល់ភាពអំណោយផលបន្ថែមសំរាប់កិច្ចព្រមព្រៀងបច្ចុប្បន្ននេះដែរ ។

## មាត្រា ១២
## ការពិគ្រោះយោបល់ និងការធ្វើវិសោធនកម្ម

១- ភាគីជាប់កិច្ចសន្យានីមួយៗ អាចស្នើឱ្យមានការជួបពិគ្រោះយោបល់លើរាល់បញ្ហា ដែលទាក់ទងនឹងកិច្ចព្រមព្រៀងនេះ ។ ភាគីម្ខាងទៀតត្រូវផ្តល់ការយកចិត្តទុកដាក់ចំពោះសំណើនេះ ហើយត្រូវផ្តល់ពេលវេលាគ្រប់គ្រាន់ សំរាប់ការពិគ្រោះយោបល់នោះផង ។

២- កិច្ចព្រមព្រៀងនេះអាចធ្វើវិសោធនកម្មគ្រប់ពេលវេលា បើសិនមានការចាំបាច់ ដោយមានការយល់ព្រមពីភាគីជាប់កិច្ចសន្យាទាំងពីរ ។

៣- ភាគីជាប់កិច្ចសន្យាណាមួយ មានបំណងធ្វើវិសោធនកម្ម ឬកែសំរួលកិច្ចព្រមព្រៀងនេះឡើងវិញ ត្រូវលើកសំណើរជាលាយលក្ខអក្សរជាផ្លូវការ ជូនភាគីជាប់កិច្ចសន្យាមួយទៀតតាមរយៈការទូត ។

## មាត្រា ១៣
## ការចូលជាធរមាន ថេរវេលា និងការបញ្ចប់

១- កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមាននៅថ្ងៃទី១ នៃខែបន្ទាប់ ក្រោយពីបានទទួលការជូនដំណឹងចុងក្រោយជាលាយលក្ខណ៍អក្សរពីភាគីជាប់កិច្ចសន្យាតាមរយៈការទូតថា តំរូវការផ្នែកច្បាប់ក្នុងប្រទេសសំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងត្រូវបានបំពេញរួចរាល់ហើយ ។

២- កិច្ចព្រមព្រៀងនេះមានសុពលភាពអនុវត្តរយៈពេលដប់ (១០) ឆ្នាំ។ សុពលភាពនៃកិច្ចព្រមព្រៀងនេះត្រូវបន្តជាធរមាន រហូតដល់ភាគីជាប់កិច្ចសន្យាណាមួយ បានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីជាប់កិច្ចសន្យាម្ខាងទៀត ពីគោលបំណងរបស់ខ្លួនថា ចង់បញ្ចប់កិច្ចព្រមព្រៀងនេះ ។ សេចក្តីជូនដំណឹងពីការបញ្ចប់សុពលភាព នៃកិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានរយៈពេលមួយឆ្នាំក្រោយថ្ងៃជូនដំណឹង ។

៣- ចំពោះការវិនិយោគដែលបានធ្វើមុនថ្ងៃ ដែលការជូនដំណឹងពីការបញ្ចប់កិច្ចព្រមព្រៀងនេះចូលជាធរមាន ខ្លឹមសារនានានៃមាត្រា ១ ដល់ មាត្រា ១២ ត្រូវស្ថិតនៅជាធរមានបន្តសំរាប់រយៈពេលដប់ (១០) ឆ្នាំទៀត ដោយគិតចាប់ពីថ្ងៃបញ្ចប់កិច្ចព្រមព្រៀងនេះ ។

ជាសាក្សីនៃកិច្ចព្រមព្រៀង តំណាងស្របច្បាប់ដែលរដ្ឋាភិបាលរបស់ខ្លួនបានប្រគល់អំណាចត្រឹមត្រូវ មានសិទ្ធិគ្រប់គ្រាន់ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅក្រុងវៀងច័ន្ទ នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ជាពីរច្បាប់ដើម ជាភាសាខ្មែរ ភាសាឡាវ និងភាសាអង់គ្លេស ហើយអត្ថបទទាំងនេះមានតំលៃគតិយុត្តិស្មើៗគ្នា ។ ក្នុងករណីមានការបកស្រាយមិនស្របគ្នា អត្ថបទជាភាសាអង់គ្លេស ត្រូវបានយកមកធ្វើជាសំអាង ។

**តាងនាមរាជរដ្ឋាភិបាលកម្ពុជា**

**ហោ ណាំហុង**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**តាងនាមរដ្ឋាភិបាល នៃសាធារណរដ្ឋ**
**ប្រជាធិបតេយ្យប្រជាមានិតឡាវ**

**ថងលុន ស៊ីស៊ុលីត**
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងការបរទេស**

# AGREEMENT
# BETWEEN
# THE ROYAL GOVERNMENT OF CAMBODIA
# AND
# THE GOVERNMENT OF THE LAO PEOPLE'S DEMOCRATIC REPUBLIC
# CONCERNING THE PROMOTION AND PROTECTION OF INVESTMENTS

The Royal Government of Cambodia and the Government of the Lao People's Democratic Republic (hereinafter referred to as "Contracting Parties");

Bearing in mind the friendly and cooperative relations existing between the two countries and their peoples;

Intending to create favourable conditions for investments by nationals of one Contracting Party on the basis of sovereign equality and mutual benefit; and

Recognizing that the Agreement on the Promotion and Protection of such Investments will be conducive to the stimulation of investment activities in both countries;

**Have agreed as follows:**

## ARTICLE I

## DEFINITIONS

For the purpose of this Agreement:

1. The term "**investment**" shall mean any kind of asset invested by nationals of one Contracting Party in the territory of the other Contracting Party and admitted, in conformity with the laws and regulations of the latter, including, but not exclusively:

    a. movable and immovable property as well as other rights such as mortgages, privileges, and guarantees and any other similar rights;

    b. rights derived from shares, bonds or any other form of interest in companies in the territory of the other Contracting Party;

    c. claims derived from shares, bonds or any performance having a financial value;

    d. intellectual property rights, technical processes, goodwill and know-how;

e. business concessions having an economic value conferred by law or under contract related to investment including concessions to search for or exploit natural resources.

Any alteration of the form in which assets are invested shall not affect their character as an investment, provided that such alteration has also been approved or admitted under Article II.

2. The term "**national**" shall mean:

(i) natural persons having the nationality of that Contracting Party;

(ii) legal persons constituted under the law of that Contracting Party.

3. The term "**without delay**" shall mean such period as is normally required for the completion of the necessary formalities for the transfer of payment.

4. The term "**territory**" shall mean:

a. In respect of the Kingdom of Cambodia: the territory of the Kingdom of Cambodia, as well as those maritime areas, including the seabed and subsoil adjacent to the outer limit of territorial sea over which the Kingdom of Cambodia exercise in accordance with international law, sovereign rights or jurisdiction;

b. In respect of the Lao People's Democratic Republic: all the territory over which the Lao People's Democratic Republic has sovereignty or jurisdiction in accordance with International Law.

5. The term "**returns**" shall mean the amounts yielded by an investment for a definite period of time as profits, interest, capital gains, dividends, royalties, fees and other legitimate returns.

6. The term "**freely usable currency**" shall means the United States Dollar, Pound Sterling, Deutschemark, French Franc, Japanese Yen or any currency that is widely used to make payments for international transactions and widely traded in the international principal exchange markets.

## ARTICLE II

## PROMOTION AND PROTECTION OF INVESTMENTS

1. Either Contracting Party shall encourage and create favourable conditions for nationals of the other Contracting Party to invest in its territory, and shall admit such investment in accordance with its Constitution, laws and regulations.

2. Investments of nationals of either Contracting Party shall at all times be accorded fair and equitable treatment and shall enjoy adequate protection and security in the territory of the other Contracting Party.

## ARTICLE III

## MOST- FAVOURED-NATION PROVISIONS

1. Each Contracting Party shall ensure fair and equitable treatment of the investments of nationals of the other Contracting Party and shall not impair, by unreasonable or discriminatory measures, the operation, management, maintenance, use, enjoyment or disposal thereof by those nationals. Each Contracting Party shall accord to such investment adequate physical security and protection.

2. More particularly, each Contracting Party shall accord to such investments treatment which in any case shall not be less favourable than that accorded to investments of nationals of any third state.

3. If a Contracting Party has accorded special advantages to nationals of any third state by virtue of existing or future agreements establishing customs unions, economic unions, monetary unions or similar institutions that Contracting Party shall not be obliged to accord such advantages to nationals of the other Contracting Party.

4. The provision of this Article shall not apply to matters of taxation in the territory of either Contracting Party. Such matters shall be governed by an Avoidance of Double Taxation Treaty between the two Contracting Parties and the domestic laws of each Contracting Party.

## ARTICLE IV

## EXPROPRIATION

Each Contracting Party shall not take any measures of expropriation, nationalization, or any other dispossession, having effect equivalent to nationalization or expropriation against the investments of a national of the other Contracting Party except under the following conditions:

a. the measures are taken for a lawful purpose, for public interest and under due process of law;

b. the measures are non discriminatory;

c. the measures are accompanied by provisions for the payment of prompt, adequate and effective compensation. Such compensation shall amount to the fair market value of the investments affected immediately before the measures of expropriation became a public knowledge. Such market value shall be determined in accordance with internationally acknowledged practices and methods or, where such fair market value cannot be determined, it shall be such reasonable amount as may be mutually agreed between the Contracting Parties hereto, and it shall be freely transferable in freely usable currencies from the Contracting Party.

## ARTICLE V

## COMPENSATION FOR LOSSES

1. Nationals of one Contracting Party, whose investments in the territory of the other Contracting Party suffer losses owing to war or other armed conflict, revolution, a state of national emergency, revolt, insurrection or riot in the territory of the latter Contracting Party, shall be accorded by the latter Contracting Party treatment, as regards restitution, indemnification, compensation or other settlement.

2. The treatment shall not be less favourable than that which the latter Contracting Party accords to its own nationals or nationals of any third State, whichever is more favourable to the nationals concerned.

## ARTICLE VI

## TRANSFERS

1. Each Contracting Party shall, subject to its laws and regulations, allow without unreasonable delay the free transfer of investments made by nationals of the other Contracting Party. Such transfer shall include, in particular, though not exclusively:

   a. profits, interests, dividends and other current income accruing from investments;

   b. funds necessary:

      (i) for the acquisition of raw or auxiliary materials, semi- fabricated or finished products; or

      (ii) to replace capital assets in order to safeguard the continuity of an investment;

   c. additional funds necessary for the development of an investment;

   d. funds in repayment of loans related to the admitted investments;

   e. royalties or fees;

   f. earnings of natural persons;

   g. proceeds accruing from sale or liquidation of the investment;

   h. compensation for losses pursuant to Article 5;

   i. compensation for expropriation pursuant to Article 4.

2. Any transfer under this Agreement shall be made in freely convertible currencies. The exchange rate applicable to such transfer in the paragraph 1 of this Article shall be the rate of exchange prevailing at the time of remittance.

## ARTICLE VII

## SUBROGATION

In case one Contracting party has granted any insurance or guarantee agreement against non-commercial risks in respect of an investment made by its own investors in the territory of the other Party and has made payments to such investors under the guarantee, the other Party shall recognize the transfer of the economic rights of the investors to said Contracting Party. The subrogation will make it possible for one Contracting Party to receive payments for compensation that the investor would have been entitled to. This does not necessary imply, however, a recognition on the part of the other Contracting Party of the merits of any case or the amount of any claim arising therefrom.

In respect of property rights or any other rights derived from ownership of the investment, subrogation will take place after the legal requirements of the investments of the host Party of the investment have been met.

## ARTICLE VIII

## SETTLEMENT OF DISPUTES BETWEEN A NATIONAL AND A CONTRACTING PARTY

1. Any dispute between a Contracting Party and a national of the other Contracting Party, concerning an investment of the latter in the territory of the former, shall be settled amicably through consultations and negotiations.

2. If such a dispute cannot be settled within a period of six months from the date of the written notification by either Party who requested amicable settlement, the dispute shall, at the request of the national concerned, be submitted either to the judicial procedures provided by the Contracting Party concerned or to international arbitration or conciliation.

3. In case the dispute is submitted to arbitration or conciliation the national shall be entitled to refer the dispute to:

   (a) The International Center for the Settlement of Investment Disputes under the Convention on the Settlement of Investment Disputes between States and Nationals of other States, opened for signature at Washington D.C, on 18 March 1965, in case both Contracting Parties have become the Parties to the Convention; or

   (b) An ad hoc tribunal to be established under the arbitration rules of the United Nations Commission on International Trade Law (UNCITRAL). An arbitral award shall be final and binding on both parties to the dispute.

4. Neither Contracting Party shall pursue through diplomatic channels any matter referred to arbitration until the proceedings have terminated or a Contracting Party has failed to abide by or comply with the award rendered by an arbitral tribunal.

## ARTICLE IX

## SETTLEMENT OF DISPUTES BETWEEN THE CONTRACTING PARTIES

1. Disputes between the Contracting Parties concerning the interpretation or application of this Agreement should, if possible, be amicably settled through diplomatic channels.

2. If disputes between the Contracting Parties cannot thus be settled, it shall, upon the request of either Contracting Party be submitted to an arbitral tribunal.

3. Such an arbitral tribunal shall be constituted for each individual case in the following way. Within two months of receipt of the request for arbitration, each Contracting Party shall appoint one member of the tribunal. Those two members shall then select a national of a third State which has diplomatic relations with both Contracting Parties and who on approval by the Contracting Parties shall be appointed Chairman of the Tribunal. The Chairman shall be appointed within two months from the date of appointment of the other two members.

4. If within the period specified in paragraph 3 of this Article the necessary appointments have not been made, either Contracting Party may, in the absence of any other Agreement, invite the President of the International Court of Justice to make any necessary appointment. If the President is a national of either Contracting Party or if he is otherwise prevented from discharging the said function, the Vice-President shall be invited to make a necessary appointment. If the Vice-President is a national of either Contracting Party or he is also prevented from discharging the said function, the member of the International Court of Justice next in seniority who is not a national of either Contracting Party shall be invited to make the necessary appointments.

5. The arbitral tribunal shall determine its own procedure and shall reach its decision by a majority of votes. Such decision shall be binding on both Contracting Parties.

6. Each Contracting Party shall bear the cost of its own member of the Tribunal and of its representation in an arbitral proceeding; the cost of the Chairman and the remaining costs shall be borne in equal parts by the Contracting Parties. The Tribunal may, however, in its decision direct that a higher proportion of costs shall be borne by one of the two Contracting Parties, and its award shall be binding on both Contracting Parties.

## ARTICLE X

## APPLICABILITY OF THIS AGREEMENT

This Agreement shall apply to investments made and admitted in the territory of either Contracting Party in accordance with its laws and regulations concerning foreign investment or any law amending or replacing it, but shall not apply to any dispute, claim or difference which arose before its entry into force.

## ARTICLE XI

## APPLICATION OF OTHER PROVISIONS

If the provisions of law of either Contracting Party or obligations under international law existing at present or established hereafter between the Contracting Parties in addition to the present Agreement contain a regulation, whether general or specific, entitling investments by nationals of the other Contracting Party to a treatment more favourable than is provided for by the present Agreement, such regulation shall to the extent that it is more favourable prevail over the present Agreement.

## ARTICLE XII

## CONSULTATION AND AMENDMENT

1. Either Contracting Party may request that consultations be held on any matter concerning this Agreement. The other Party shall accord sympathetic consideration to the proposal and shall afford adequate opportunity for such consultations.

2. This Agreement may be amended at any time, if deemed necessary, by mutual consent of both Contracting Parties.

3. Any Contracting Party wishing to amend or revise the Agreement shall make an official written request to the other Contracting Party through diplomatic channels.

## ARTICLE XIII

## ENTRY INTO FORCE, DURATION AND TERMINATION

1. This Agreement shall enter into force on the first day of the following month after the date of the later notification by the Contracting Parties in writing, through diplomatic channels, that their internal legal requirements for the entry into force of the Agreement has been complied with.

2. This Agreement shall remain in force for a period of ten (10) years. It shall remain in force thereafter until either Contracting Party notifies the other Contracting Party in writing of the intention to terminate this Agreement. The notice of the termination shall become effective one year after the date of notification.

3. In respect of investments made prior to the date when the notice of termination of this Agreement becomes effective, the provisions of Articles I to XII shall remain in force for a further period of ten (10) years from the date of termination of the present Agreement.

**IN WITNESS WHEREOF**, the undersigned, duly authorized thereto by their respective Governments, have signed this Agreement.

Done in Vientiane on November 24th, 2008 in two originals in Khmer, Lao and English, all texts are equally authentic. In case of any divergence in interpretation, the English text shall prevail.

| FOR THE ROYAL GOVERNMENT OF CAMBODIA | FOR THE GOVERNMENT OF THE LAO PEOPLE'S DEMOCRATIC REPUBLIC |
|---|---|
|  |  |
| **HOR Namhong**<br>**Deputy Prime Minister,**<br>**Minister of Foreign Affairs and International Cooperation** | **Thongloun SISOULITH**<br>**Deputy Prime Minister,**<br>**Minister of Foreign Affairs** |

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៩៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានតែងតាំងលោកជំទាវ **ស៊ិន ចរិយាសម្ផស្ស** ជាទីប្រឹក្សាក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៦៥៥ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ២០០៩
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**ឃុន ជិនកេន**

៣រល.០៩០៦.៧០៥

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៩*

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៦៩៥

**យើង**

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**

**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**

**ខេមរាជនា សម្ហោរភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**

**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានតែងតាំង :

១.- ឯកឧត្តម **អ៊ឹុ សម្បូរណ៍** ជាប្រធានលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល មានឋានៈស្មើ **អគ្គនាយក** ។

២.- ឯកឧត្តម **យឹម សុគន្ធ** ជាអនុប្រធានលេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ចរល.០៩០៦.៧០៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៩*

លេខៈ ៦៥៤ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០០៩

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៧០២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០១០៩/០២៦ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអេស្កាប់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.** តែងតាំងឯកឧត្តម **ចាន់ យ៉ុន ជូ** ជាជំនួយការឯកឧត្តម **លី ធុជ** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានគណៈកម្មាធិការជាតិអេស្កាប់ មានឋានៈស្មើ **អគ្គនាយក** ជំនួសឯកឧត្តម **ចៅ ឡាយ** ដែលត្រូវបានទទួលភារកិច្ចថ្មី ។

**មាត្រា ២.** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៩០៦.៧១០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៩*

លេខៈ ៦២៨ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០០៩
**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**
**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៦០៩/៧០៤

## យើង

